កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Co-financed by:
Australian Embassy
Cambodia

# សេចក្តីប្រកាសព័ត៌មានរួម
# រដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋាភិបាល នៃសាធារណៈសហព័ន្ធអាល្លឺម៉ង់
# សហការគាំទ្ររាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាក្នុងការលើកកម្ពស់
# សេវាគាំពារសង្គមនិងសុខភាពនៅក្នុងប្រទេសកម្ពុជា

**រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា** – រដ្ឋាភិបាលអូស្ត្រាលី និងទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស (GIZ) បានចុះហត្ថលេខាជាផ្លូវការលើគំនិតផ្តួចផ្តើមមួយដែលមានគោលបំណងពង្រឹងប្រព័ន្ធគាំពារសង្គម និងវិស័យសុខាភិបាលនៅប្រទេសកម្ពុជា។ ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) របស់ប្រទេសអូស្ត្រាលីកំពុងចាប់ដៃគូជាមួយក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(BMZ) នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដើម្បីផ្តល់មូលនិធិដល់គម្រោង "លើកកម្ពស់គាំពារសង្គម និងសុខភាព ដំណាក់កាលទី២"។

សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ផ្តល់ថវិកាចំនួន ៩,៧ លានអឺរ៉ូ ហើយប្រទេសអូស្ត្រាលីសហការផ្តល់ថវិកាវិភាគទានចំនួន ៤,៥ លានដុល្លារអូស្ត្រាលី ដល់គម្រោងខាងលើនេះដែលនឹងដំណើរការ រហូតដល់ខែកញ្ញា ឆ្នាំ២០២៧។ សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រទេសអូស្ត្រាលីសហការគ្នា ដើម្បីគាំទ្ររាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាក្នុងការពង្រឹងកិច្ចគាំពារសង្គម និងសេវាសុខាភិបាល។

ជាការឆ្លើយតបទៅនឹងតម្រូវការពីភាគីកម្ពុជា គម្រោងនេះផ្តោតលើវិស័យអាទិភាពនានារបស់ប្រទេសអូស្ត្រាលី និងសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងផ្អែកលើកិច្ចសហប្រតិបត្តិការកិច្ចគាំពារសង្គមដែលបានអនុវត្តនាពេលកន្លងមក។ គម្រោងនេះផ្តោតលើផ្នែកសំខាន់ៗ រួមទាំងការ បញ្ចូលនូវប្រព័ន្ធគាំពារសង្គម និងការប្រែប្រួលអាកាសធាតុ ការឆ្លើយតបយេនឌ័រ និងការរាប់បញ្ចូលជនមានពិការភាពនៅក្នុងប្រព័ន្ធគាំពារសង្គម និងវិស័យសុខាភិបាល។ GIZ នឹងអនុវត្តគម្រោងដោយផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍគោលនយោបាយ ការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍន៍សមត្ថភាពអ្នកអនុវត្តកម្មវិធី និងបង្កើតឱ្យមានជាទឡ្ហីករណ៍ជាក់ស្តែង ដើម្បីជាព័ត៌មានសម្រាប់អ្នករៀបចំគោលនយោបាយ និងប្រតិបត្តិករ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើរតួនាទីជាដៃគូចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់គម្រោងនេះ។ ក្រុមការងារ GIZ ធ្វើការយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិការពារសង្គម និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត រួមមាន ក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសុខាភិបាល មូលនិធិជាតិជំនួយសង្គម បេឡាជាតិសន្តិសុខសង្គម ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ និយ័តករសន្តិសុខសង្គម និងភាគីផ្សេងៗទៀត។

លោកស្រី Bridget Collier ភារៈធារីស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា "តាមរយៈកិច្ចសហប្រតិបត្តិការនេះ យើងមានគោលបំណងផ្តល់នូវដំណោះស្រាយដែលនឹងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគាំពារសង្គមនៃប្រទេសកម្ពុជា និងផ្តល់នូវសេវាចាំបាច់សំខាន់ៗសម្រាប់ប្រជាពលរដ្ឋដែលត្រូវការជំនួយ។ លោកស្រីបន្តថា "ស្របតាមអាទិភាពនៃការអភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលី គម្រោងនេះនឹងផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីដោះស្រាយភាពក្រីក្រ និងវិសមភាព ពង្រីកចលនាសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព"។

លោក Jost Kadel អនុប្រធានបេសកកម្ម និងជាប្រធានផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ នៃស្ថានទូតសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំរាជធានីភ្នំពេញបានមានប្រសាសន៍ថា "យើងមានមោទនភាពក្នុងការចាប់ដៃគូជាមួយរដ្ឋាភិបាលអូស្ត្រាលីលើគំនិតផ្តួចផ្តើមដ៏សំខាន់នេះ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នារបស់យើងក្នុងការលើកកម្ពស់កិច្ចគាំពារសង្គម និងប្រព័ន្ធសុខាភិបាលនៅកម្ពុជា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ យើងអាចធានាថា ប្រជាពលរដ្ឋដែលងាយរងគ្រោះទទួលបាននូវការគាំទ្រដែលគាត់ត្រូវការ ជំរុញនូវភាពធន់ និងលើកកម្ពស់កំណើនបរិយាប័ន្ននៅក្នុងតំបន់"។

GIZ ដែលត្រូវបានទទួលស្គាល់ថាជាទីភ្នាក់ងារដែលមានជំនាញក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព នឹងប្រើប្រាស់ធនធាន និងបទពិសោធន៍យ៉ាងទូលំទូលាយរបស់ខ្លួនក្នុងការអនុវត្តគម្រោងគាំពារសង្គមនិងសុខភាព ដើម្បីធានាបាននូវភាពជោគជ័យនៃគំនិតផ្តួចផ្តើមនេះ។ លោកស្រី Kristina Knispel នាយកគម្រោងលើកកម្ពស់គាំពារសង្គម និងសុខភាព ដំណាក់កាលទី២ នៅក្នុងប្រទេសកម្ពុជាបានមានប្រសាសន៍ថា "យើងមានសេចក្តីសោមនស្សរីករាយក្នុងការចាប់ដៃគូជាមួយប្រទេសអូស្ត្រាលីក្នុងការអនុវត្តគម្រោងដ៏មានសារៈសំខាន់នេះ និងសូមថ្លែងអំណរគុណចំពោះការជឿទុកចិត្តដែលដៃគូផ្តល់មូលនិធិនៅក្នុងកិច្ចការងារនេះ"។ លោកស្រីបានបន្តថា "ការធ្វើកិច្ចសហការរួមគ្នា យើងអាចបង្កើតផលជះ ប្រកបដោយនិរន្តរភាពដែលគាំទ្រដល់សុខភាព និងសុខុមាលភាពសង្គមរបស់សហគមន៍"។

ការគាំទ្រសហហិរញ្ញប្បទាននេះនឹងផ្តល់លទ្ធភាពឱ្យគម្រោង "លើកកម្ពស់គាំពារសង្គម និងសុខភាព ដំណាក់កាលទី២" អាចអនុវត្តការគាំទ្រ ស្របតាមតម្រូវការរបស់ដៃគូ និងអនុវត្តវិធីសាស្ត្រនានាប្រកបដោយភាពច្នៃប្រឌិត។ តាមរយៈការជំរុញឱ្យមានកិច្ចសហការគ្នានៅតាមស្ថាប័ន និងប្រតិបត្តិករ

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Co-financed by:
Australian Embassy
Cambodia

របស់រាជរដ្ឋាភិបាលកម្ពុជា និងក្នុងចំណោមសហគមន៍នានា គម្រោងនេះមានគោលបំណងគាំទ្រដល់ការអភិវឌ្ឍ ប្រកបដោយចីរភាព និងជាប្រព័ន្ធ នៃវិស័យគាំពារសង្គម និងសុខាភិបាល។

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង "លើកកម្ពស់គាំពារសង្គម និងសុខភាព ដំណាក់កាលទី២" សូមចូលទៅកាន់គេហទំព័ររបស់ GIZ ៖ Making social protection and health services gender just and crisis proof - giz.de និងបណ្ណព័ត៌មានរបស់គម្រោង តាមរយៈ giz2024-en-ISPH-II-factsheet.pdf.

ព័តមានបន្ថែមអំពីការចូលរួមរបស់ GIZ នៅក្នុងប្រទេសកម្ពុជា អាចរកបាននៅទីនេះ៖ Cambodia - giz.de

ព័ត៌មានបន្ថែមអំពីការចូលរួមរបស់ DFAT នៅក្នុងប្រទេសកម្ពុជា អាចរកបាននៅទីនេះ here

---

ទំនាក់ទំនងព័ត៌មាននៅស្ថានទូតអូស្ត្រាលី ប្រចាំកម្ពុជា
Media.Cambodia@dfat.gov.au

ទំនាក់ទំនងព័ត៌មាននៅស្ថានទូតអាល្លឺម៉ង់ ប្រចាំកម្ពុជា
លោក Jost Kadel
ភារធារី និងជាប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
ស្ថានទូតអាល្លឺម៉ង់ ប្រចាំកម្ពុជា
v@phno.auswaertiges-amt.de

ទំនាក់ទំនងព័ត៌មាននៅ GIZ ប្រចាំកម្ពុជា
កញ្ញា គី សុវណ្ណារី
មន្ត្រីឯកទេសផ្នែកទំនាក់ទំនង
GIZ ប្រចាំកម្ពុជា
sovannary.ky@giz.de